**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៨-០៦៣ ប្រ.ក

# ប្រកាស
## ស្តីពី
## ការតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

ចុះបញ្ជី
ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៨

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- បានឃើញបទប្បញ្ញត្តិលេខធ៧៩៧-០២បប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីវិសោធនកម្មលើលក្ខខណ្ឌនៃការតម្កល់ប្រាក់បំរុងកាតព្វកិច្ច លើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីផងការផ្សេងៗ ដោយស្ថាប័ន រូបិយវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨

## ស ម្រេ ច

**ប្រការ ១.-**

ធនាគារពាណិជ្ជ ត្រូវតម្កល់ប្រាក់បំរុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចី ជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា ស្មើនឹងប្រាំបីភាគរយ(៨%)ចំពោះប្រាក់រៀល និងដប់ប្រាំមួយភាគរយ(១៦%)ចំពោះ ប្រាក់រូបិយប័ណ្ណ។

**ប្រការ ២.-**

ធនាគារជាតិនៃកម្ពុជានឹងផ្តល់កំរៃការប្រាក់ ដូចខាងក្រោម :

- ចំពោះប្រាក់បំរុងកាតព្វកិច្ចជាប្រាក់រៀលចំនួនប្រាំបីភាគរយ (៨%) មានអត្រាការប្រាក់សូន្យភាគរយ (0%)
- ចំពោះប្រាក់បំរុងកាតព្វកិច្ចជាប្រាក់រូបិយប័ណ្ណចំនួនដប់ប្រាំមួយភាគរយ (១៦%) ក្នុងនោះ ប្រាំបីភាគរយ (៨%)មានអត្រាការប្រាក់សូន្យភាគរយ (0%) និងប្រាំបីភាគរយ (៨%) បន្ថែមទៀត ផ្តល់អត្រាការប្រាក់បីភាគបួន (៣/៤) ស្មើនឹង 0,៧៥នៃអត្រា SIBOR គិតលើមូលដ្ឋានមួយខែ។

**ប្រការ ៣.-**

ធនាគារពាណិជ្ជដែលទទួលរងឱនភាពប្រាក់បំរុងកាតព្វកិច្ច ត្រូវទទួលរងការផាកពិន័យ ស្មើនឹងសូន្យក្បៀសមួយភាគរយ (0,១%) នៃប្រាក់ដែលទទួលរងឱនភាព ។ ធនាគារពាណិជ្ជណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុង មាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ ៤.-**

បទប្បញ្ញត្តិលេខធ៧៩៧-០២បប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីវិសោធនកម្មលើលក្ខខណ្ឌនៃការតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ដោយស្ថាប័នរូបិយវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីរយៈពេលមូលដ្ឋានពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ តទៅ អនុលោមតាមសារាចរណែនាំលេខធ៧-០៧-០១ សរណន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីរយៈពេលមូលដ្ឋាន និងរយៈពេលដែលត្រូវតម្កល់និងថ្ងៃរាយការណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័តិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7-08-063 Prokor

Unofficial Translation

# PRAKAS
## on
## The Maintenance of Reserve Requirements against Commercial Banks' Deposits and Borrowings

### The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0904/244 of September 7, 2004, on the appointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to the Regulation No B797-02 dated December 26, 1997, on the amendment of the Maintenance of Required Reserves Against Deposits and other Borrowings for the Financial Institutions;
- Pursuant to the recommendation made by National Bank of Cambodia management during the April 21, 2008, meeting.

### DECIDES

**Article 1**

Commercial Banks shall maintain reserve requirements against deposits and borrowings at a daily average balance equal to eight percent (8%) in Riels and sixteen percent (16%) in foreign currencies with the National Bank of Cambodia.

**Article 2**

The National Bank of Cambodia will provide interest fees as follows:

- Reserve requirements in Riels equal to 8% will bear interest at zero percent (0%).

- For reserve requirements in foreign currencies equal to 16% : 8% will bear interest at 0%, while the remaining 8% will bear interest at 3/4, equivalent to 0.75, one month period SIBOR.

**Article 3**

Any commercial bank that persistently incurs a reserve deficiency shall be penalized by zero point one percent (0.1%) on the deficit amount. The commercial banks that are not compliant with this Prakas will be penalized according to Article 52 of the Law on Banking and Financial Institutions.

**Article 4**

The Regulation No B797-02 dated December 26, 1997, on the amendment of the Maintenance of Required Reserves Against Deposits and other Borrowings for the Financial Institutions is hereby repealed.

**Article 5**

The General Director, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banks and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 6**

This Prakas shall take effect from base period on June 27, 2008, and be compliant with the circular No B7-07-01 dated December 06, 2007, on The Base, Maintenance Periods and Reporting Due Dates.

Phnom Penh, April 25, 2008

**The Governor**

**Signed and Sealed**

cc:
- All members of the Board of Directors
- The parties concerned as stated in Article 5
- File
- CM "for info"
- Administration Department of CM
  "for publication in the National Gazette"